OneHope

GOD'S WORD. EVERY CHILD.

# ដំណើររឿងទាំង ១៧

## វគ្គបណ្តុះបណ្តាល

តើអ្នកដឹងពីដំណើររឿងទាំង ១៧ ខែរឬទេ?

- ដំណើររឿងទាំង ១៧ ត្រូវបានយកមកប្រើប្រាស់នៅក្នុងកម្មវិធីជាច្រើនដូចជា៖
  - កម្មវិធីក្លឹប
  - សាលាថ្ងៃអាទិត្យ
  - VBS
  - គ្រួសារ...

❖ គោលបំណងចម្បងរបស់ដំណើររឿងទាំង ១៧ គឺៈ

1. ការស្រឡាញ់ព្រះជាម្ចាស់តាមរយៈការសរសើរតម្កើង និងថ្វាយបង្គំ។
2. ការរៀនព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាមួយគ្នា។
3. ការស្តាប់ និងឆ្លើយតបចំពោះព្រះសូរសៀងរបស់ព្រះជាម្ចាស់។
4. ការចែករំលែកជាមួយគ្នាទៅវិញទៅមកនូវអ្វីដែលព្រះជាម្ចាស់កំពុងបង្រៀនពួកគេ។
5. ការអធិស្ឋានសម្រាប់គ្នាទៅវិញទៅមក។
6. ការប្រទានពរឲ្យគ្នាទៅវិញទៅមក ឲ្យក្លាយជាមនុស្សដែលព្រះជាម្ចាស់សព្វព្រះហឫទ័យបង្កើតមក។

OneHope
GOD'S WORD. EVERY CHILD.

## ❖ ៨ ផ្នែករបស់ដំណើររឿងទាំង ១៧ គឺ៖

1. ស្វាគមន៍
2. សរសើរតម្កើង និងថ្វាយបង្គំ
3. ការរំឭកមេរៀន និងលំនាំចូលមេរៀន
4. មេរៀនដំណើររឿងក្នុងព្រះគម្ពីរ
5. ការស្តាប់សំណូមពរអធិស្ឋាន និង ការកត់ត្រា
6. ការចែកចាយ និង ការអធិស្ឋានរួមគ្នា
7. ការសរសើរតម្កើង និងថ្វាយបង្គំ
8. ការចែកកាត


ដំណើររឿងទាំង ១៧
សម្រាប់កុមារា និង កុមារី
សៀវភៅណែនាំគ្រូ សម្រាប់ការ
ស្តីនិទានរឿងដ៏ធំរបស់ព្រះជាម្ចាស់
OneHope
GOD'S WORD. EVERY CHILD.
Pebbles Stones


ដំណើររឿងទាំង ១៧
OneHope
GOD'S WORD. EVERY CHILD.



## «ទឹកជំនន់ធំ»

ស្វាគមន៍

ការសរសើរតម្កើង និងថ្វាយបង្គំ

ហៅមកថ្វាយបង្គំ

ការរំឭកមេរៀន និងសំណួរចាប់ផ្ដើម ៖
កាលពីដើមដំបូងបង្អស់ព្រះជាម្ចាស់បានបង្កើតផែនដី និងអ្វីៗសព្វសារពើនៅលើផែនដី ហើយព្រះអង្គឃើញយល់ថាគ្រប់យ៉ាងល្អប្រសើរណាស់។ ព្រះអង្គក៏បានបង្កើតមនុស្សពីរនាក់ដំបូង គឺអាដាំ និង អេវ៉ា។

បន្ទាប់ពីអាដាំ និងអេវ៉ាបានប្រព្រឹត្តអំពើបាប កូនៗរបស់ពួកគេក៏មិនបានស្ដាប់បង្គាប់ព្រះជាម្ចាស់ដែរ។ អស់ពេលដ៏យូរលង់ ផែនដីទាំងមូលមានមនុស្សរស់នៅពាសពេញ។ ពួកគេគ្រប់គ្នាបានចាប់ផ្ដើមធ្វើកិច្ចការដែលព្រះជាម្ចាស់យល់ថាខុសឆ្គង។

លើសពីនោះទៅទៀត អំពើបាបបានកើនឡើងពាសពេញពិភពលោក រហូតដល់ព្រះជាម្ចាស់ធ្វើការសម្រេចចិត្តថានឹងបំផ្លាញផែនដីនេះចោលដោយទឹកជំនន់ធំ ដើម្បីជំរះបាប។ មុនពេលដែលអ្នកគ្រូនិទានរឿងនេះ សូមយកពេលវេលាបន្តិចដើម្បីគិតពីពេលប្អូនៗមានអារម្មណ៍ភ័យខ្លាច ហើយត្រូវការសុវត្ថិភាព។ (សូមចែកចាយចំលើយរបស់លោកអ្នក រួចហើយទុកឱកាសឱ្យគ្រប់គ្នាចែកចាយដែរ)។

ដំណើររឿង និងមេរៀន ៖ លោកុប្បត្តិ ៦-៩
ក្នុងដំណើររឿងរបស់យើងថ្ងៃនេះ ប្អូនៗនឹងឮអំពីរបៀបដែលព្រះជាម្ចាស់រក្សាក្រុមគ្រួសារមួយឱ្យមានសុវត្ថិភាពពីគ្រប់ការអាក្រក់ដែលនៅជុំវិញពួកគេ។ ដំណើររឿងបានចាប់ផ្ដើមប្រមាណ១២០ឆ្នាំ មុនពេលផែនដីមានទឹកជំនន់ធំបំផុត។

ព្រះជាម្ចាស់ទតមើលមកផែនដីដ៏ស្រស់ស្អាតនេះ ដែលទ្រង់បានបង្កើតនេះ ហើយឃើញថា មនុស្សស្ទើតែទាំងអស់បានឈប់ស្រឡាញ់ព្រះអង្គហើយក៏ឈប់ស្រឡាញ់គ្នាទៅវិញទៅមកដែរ។ គ្រប់យ៉ាងដែលពួកគេគិត និងរៀបចំផែនការសុទ្ធតែអាក្រក់។ គ្រប់គ្នានេះ គឺត្រូវបានលើកលែងចំពោះលោកណូអេ និង ក្រុមគ្រួសាររបស់លោក។

លោកណូអេបានបង្រៀនកូនៗរបស់គាត់ឱ្យស្រឡាញ់ព្រះជាម្ចាស់។ ពួកគាត់បន្តស្រឡាញ់ និងស្ដាប់បង្គាប់ព្រះជាម្ចាស់ ក្នុងពេលដែលគ្មាននរណាគេធ្វើដូចពួកគាត់។

មានថ្ងៃមួយ ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់លោកណូអេហើយបានព្រមានគាត់ថា ទ្រង់នឹងធ្វើឱ្យមានទឹកជំនន់មួយយ៉ាងធំលេចពេញផែនដី។ព្រះជាម្ចាស់បានប្រាប់លោកណូអេឱ្យធ្វើទូកមួយយ៉ាងធំ។ ព្រះអង្គក៏បានប្រាប់គាត់នូវប្រភេទឈើដែលត្រូវយកមកធ្វើទូក និងទំហំនៃទូក









«ទឹកជំនន់ធំ»

ស្វាគមន៍

ការសរសើរតម្កើង និងថ្វាយបង្គំ

ហៅមកថ្វាយបង្គំ

ការរំឭកមេរៀន និងសំណួរចាប់ផ្តើម ៖
កាលពីដើមដំបូងបង្អស់ព្រះជាម្ចាស់បានបង្កើតផែនដី និងអ្វីៗសព្វសារពើនៅលើផែនដី ហើយព្រះអង្គឃើញយល់ថាគ្រប់យ៉ាងល្អប្រសើរណាស់។ ព្រះអង្គក៏បានបង្កើតមនុស្សពីរនាក់ដំបូង គឺអាដាំ និង អេវ៉ា។

បន្ទាប់ពីអាដាំ និងអេវ៉ាបានប្រព្រឹត្តអំពើបាប កូនៗរបស់ពួកគេក៏មិនបានស្តាប់បង្គាប់ព្រះជាម្ចាស់ដែរ។ អស់ពេលដ៏យូរលង់ ផែនដីទាំងមូលមានមនុស្សរស់នៅពាសពេញ។ ពួកគេគ្រប់គ្នាបានចាប់ផ្តើមធ្វើកិច្ចការដែលព្រះជាម្ចាស់យល់ថាខុសឆ្គង។

លើសពីនោះទៅទៀត អំពើបាបបានកើនឡើងពាសពេញពិភពលោក រហូតដល់ព្រះជាម្ចាស់ធ្វើការសម្រេចចិត្តថានឹងបំផ្លាញផែនដីនេះចោលដោយទឹកជំនន់ធំ ដើម្បីជំរះបាប។ មុនពេលដែលអ្នកគ្រូនិទានរឿងនេះ សូមយកពេលវេលាបន្តិចដើម្បីគិតពីពេលប្អូនៗមានអារម្មណ៍ភ័យខ្លាច ហើយត្រូវការសុវត្ថិភាព។ (សូមចែកចាយចំលើយរបស់លោកអ្នក រួចហើយទុកឱកាសឱ្យគ្រប់គ្នាចែកចាយដែរ)។

ដំណើររឿង និងមេរៀន ៖ លោកុប្បត្តិ ៦-៩
ក្នុងដំណើររឿងរបស់យើងថ្ងៃនេះ ប្អូនៗនឹងឮអំពីរបៀបដែលព្រះជាម្ចាស់រក្សាក្រុមគ្រួសារមួយឱ្យមានសុវត្ថិភាពពីគ្រប់ការអាក្រក់ដែលនៅជុំវិញពួកគេ។ ដំណើររឿងបានចាប់ផ្តើមប្រមាណ១២០ឆ្នាំ មុនពេលផែនដីមានទឹកជំនន់ធំបំផុត។

ព្រះជាម្ចាស់ទតមើលមកផែនដីដ៏ស្រស់ស្អាតនេះ ដែលទ្រង់បានបង្កើតនេះ ហើយឃើញថា មនុស្សស្ទើរតែទាំងអស់បានឈប់ស្រឡាញ់ព្រះអង្គហើយក៏ឈប់ស្រឡាញ់គ្នាទៅវិញទៅមកដែរ។ គ្រប់យ៉ាងដែលពួកគេគិត និងរៀបចំផែនការសុទ្ធតែអាក្រក់។ គ្រប់គ្នានេះ គឺត្រូវបានលើកលែងចំពោះលោកណូអេ និង ក្រុមគ្រួសាររបស់លោក។

លោកណូអេបានបង្រៀនកូនៗរបស់គាត់ឱ្យស្រឡាញ់ព្រះជាម្ចាស់។ ពួកគាត់បន្តស្រឡាញ់ និងស្តាប់បង្គាប់ព្រះជាម្ចាស់ ក្នុងពេលដែលគ្មាននរណាគេធ្វើដូចពួកគាត់។

មានថ្ងៃមួយ ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់លោកណូអេ ហើយបានព្រមានគាត់ថា ទ្រង់នឹងធ្វើឱ្យមានទឹកជំនន់មួយយ៉ាងធំលេចពេញផែនដី។ព្រះជាម្ចាស់បានប្រាប់លោកណូអេឱ្យធ្វើទូកមួយយ៉ាងធំ។ ព្រះអង្គក៏បានប្រាប់គាត់នូវប្រភេទឈើដែលត្រូវយកមកធ្វើទូក និងទំហំនៃទូក

❖ ការហៅ…ជាមួយនឹងសំណួរៈ

- តើកន្លែងនេះជាអ្វី?
- តើយើងជានរណា?
- តើហេតុអ្វីយើងនៅទីនេះ?
- តើយើងថ្វាយបង្គំព្រះជាម្ចាស់ដោយរបៀបណា?

OneHope
GOD'S WORD. EVERY CHILD.



9

ថែមទៀតផង។ ទោះបីគ្មានទន្លេ ឬសមុទ្រនៅក្បែរផ្ទះរបស់លោកណូអេក៏ដោយ លោកណូអេបានស្តាប់បង្គាប់និងបានចាប់ផ្តើមកសាងទូកដ៏ធំមួយ ។

លោកណូអេ និងកូនៗរបស់គាត់បានចំណាយពេលអស់រយៈពេល១២០ឆ្នាំក្នុងការកសាងទូកមួយនេះ។ ប្អូនៗអាចស្រមៃមើលបានទេ ថាត្រូវធ្វើទូកដ៏ធំមួយនៅទីកណ្តាលដីស្ងួតហួតហែង? តើមនុស្សដទៃទៀតគេនឹងគិតយ៉ាងណាចំពោះលោកណូអេ និងកូនៗរបស់គាត់?

ក្នុងពេលនេះមនុស្សបានបន្តប្រឆាំងបះបោរនឹងព្រះជាម្ចាស់ ជាព្រះដែលបានបង្កើតពួកគេ។ ពួកគេបដិសេធក្នុងការប្រាប់ព្រះជាម្ចាស់ថាពួកគេសោកស្តាយចំពោះអំពើបាបរបស់ពួកគេ។ វាហាក់ដូចជាពួកគេនិយាយទៅកាន់ព្រះជាម្ចាស់ថា ៖ «កុំរវល់នឹងពួកយើងអី។ពួកយើងនឹងធ្វើអ្វីដែលយើងចង់ធ្វើ។ ពួកយើងចេះជាងព្រះអង្គទៅទៀត។»

កាលទូកបានធ្វើរួចរាល់ហើយនោះ ព្រះជាម្ចាស់បានប្រាប់លោកណូអេឱ្យនាំសត្វញីនិងឈ្មោលមួយគូៗគ្រប់ប្រភេទ ទាំងបក្សាបក្សីឱ្យចូលទៅក្នុងទូក។ ព្រះជាម្ចាស់ក៏បានណែនាំដល់ក្រុមគ្រួសាររបស់លោកណូអេឱ្យរៀបចំម្ហូបអាហារស្តុកទុកសម្រាប់ពួកគេ និងហ្វូងសត្វ។

នៅថ្ងៃទី៧បន្ទាប់ពីលោកណូអេ និងក្រុមគ្រួសាររបស់លោកចូលទៅក្នុងទូក ព្រះជាម្ចាស់បានបិទទ្វារទូក។ ភ្លាមៗនោះស្រាប់តែភ្លៀងបង្អុរចុះមក។ ភ្លៀងបន្តអស់រយៈពេល៤០យប់៤០ថ្ងៃ! វាភ្លៀងមិនឈប់ឈររហូតដល់ទៅលេចភ្នំទាំងឡាយអស់។

មានក្រុមគ្រួសាររបស់លោកណូអេ និងហ្វូងសត្វដែលពួកលោកបានប្រមូលចូលទូកតែប៉ុណ្ណោះដែលរស់រានមានជីវិត។ លោកណូអេទាំងប្រពន្ធ និងកូនប្រុសៗ ព្រមទាំងកូនប្រសាស្រីៗរបស់គាត់ដែលបានទទួលសុវត្ថិភាព ពីព្រោះពួកគេបានជ្រើសរើសស្តាប់បង្គាប់ព្រះជាម្ចាស់យ៉ាងអស់ពីចិត្ត។

នៅទីបញ្ចប់ភ្លៀងក៏ឈប់ ហើយទឹកក៏បានស្រក។ លោកណូអេ និងក្រុមគ្រួសាររបស់លោក ព្រមទាំងហ្វូងសត្វបានចេញពីទូកឈានជើងលើផែនដីជាថ្មីម្តងទៀត។

តើប្អូនៗដឹងទេថាតើកិច្ចការដំបូងបង្អស់ដែលពួកគេបានធ្វើគឺជាអ្វី? គឺពួកគេថ្វាយបង្គំ និងថ្លែងអំណរព្រះគុណដល់ព្រះជាម្ចាស់!

បន្ទាប់មកព្រះជាម្ចាស់បានដាក់ឥន្ទធនូនៅលើមេឃ ហើយបានចងព្រះបន្ទូលសន្យាមួយយ៉ាងអស្ចារ្យគឺថា ៖ យើងនឹងប្រទានពរឱ្យដល់អ្នក។ ចូរបង្កើតកូនចៅឱ្យបានច្រើនពាសពេញផែនដី។ ឥន្ទធនូដែលយើងដាក់នៅលើមេឃនេះនឹងក្លាយជាសញ្ញាដល់អ្នក ថាផែនដីនេះនឹងមិនត្រូវបំផ្លាញដោយទឹកជំនន់ទៀតទេ។

លោកណូអេ និងក្រុមគ្រួសាររបស់លោកត្រូវបានសុវត្ថិភាពដោយសារព្រះជាម្ចាស់ដែលពួកគេស្រឡាញ់!

| |
|---|
| *ខចងចាំ ៖ «ព្រះអម្ចាស់មានព្រះបន្ទូលថា៖ ដោយគេស្អិតនៅជាប់នឹងយើង យើងនឹងជួយរំដោះគេ យើងនឹងការពារគេព្រោះគេទទួលស្គាល់ថា យើងជាព្រះអម្ចាស់។» ទំនុកតម្កើង ៩១:១៤។* |

សង្ខេប ៖ព្រះជាម្ចាស់បានចាត់ឱ្យមានទឹកជំនន់មួយដ៏ធំ ដោយព្រោះតែកិច្ចការអាក្រក់ដែលមនុស្សលោកបានប្រព្រឹត្តនៅលើផែនដី។ ព្រះជាម្ចាស់បានរក្សាជីវិតលោកណូអេ និងក្រុមគ្រួសាររបស់លោកឱ្យបានសង្គ្រោះ ដោយព្រោះតែពួកគេជឿទុកចិត្តលើព្រះអង្គ។ មិនថាមានអ្វីកើតឡើងនៅជុំវិញយើងនោះទេ ព្រះជាម្ចាស់នឹងការពារយើង ពេលយើងជឿទុកចិត្តលើព្រះអង្គ និងស្តាប់បង្គាប់ព្រះអង្គយ៉ាងអស់ពីចិត្ត។

ការកត់ត្រា និងការស្តាប់សំណូមពរអធិស្ឋាន

ការចែកចាយ និងការអធិស្ឋានរួមគ្នា

ការសរសើរតម្កើង និងថ្វាយបង្គំ

ការប្រទានពរ និងបញ្ចប់កម្មវិធី ៖
អ្នកគ្រូសូមជូនពរប្អូនៗឱ្យស្គាល់ព្រះជាម្ចាស់ និងឱ្យបទពិសោធការការពារថែរក្សារបស់ព្រះអង្គ។

# 5.ការស្តាប់សំណូមពរអធិស្ឋាន និង ការកត់ត្រា

- តើដំណើររឿងនេះប្រាប់យើងអ្វីអំពីព្រះយេស៊ូ?
- តើដំណើររឿងនេះប្រាប់យើងអ្វីអំពីខ្លួនឯង?
- តើដំណើររឿងនេះប្រាប់យើងអ្វីអំពីអ្នកដ៏ទៃ?
- តើដំណើររឿងនេះប្រាប់យើងអោយធ្វើអ្វី?





ថែមទៀតផង។ ទោះបីគ្មានទន្លេ ឬសមុទ្រនៅក្បែរផ្ទះរបស់លោកណូអេក៏ដោយ លោកណូអេបានស្តាប់បង្គាប់និងបានចាប់ផ្តើមកសាងទូកដ៏ធំមួយ ។

លោកណូអេ និងកូនៗរបស់គាត់បានចំណាយពេលអស់រយៈពេល១២០ឆ្នាំក្នុងការកសាងទូកមួយនេះ។ ប្អូនៗអាចស្រមៃមើលបានទេ ថាត្រូវធ្វើទូកដ៏ធំមួយនៅទីកណ្តាលដីស្ងួតហួតហែង ? តើមនុស្សដទៃទៀតគេនឹងគិតយ៉ាងណាចំពោះលោកណូអេ និងកូនៗរបស់គាត់ ?

ក្នុងពេលនេះមនុស្សបានបន្តប្រឆាំងបះបោរនឹងព្រះជាម្ចាស់ ជាព្រះដែលបានបង្កើតពួកគេ។ ពួកគេបដិសេធក្នុងការប្រាប់ព្រះជាម្ចាស់ថាពួកគេសោកស្តាយចំពោះអំពើបាបរបស់ពួកគេ។ វាហាក់ដូចជាពួកគេនិយាយទៅកាន់ព្រះជាម្ចាស់ថា ៖ «កុំរវល់នឹងពួកយើងអី។ពួកយើងនឹងធ្វើអ្វីដែលយើងចង់ធ្វើ។ ពួកយើងចេះជាងព្រះអង្គទៅទៀត។»

កាលទូកបានធ្វើរួចរាល់ហើយនោះ ព្រះជាម្ចាស់បានប្រាប់លោកណូអេឱ្យនាំសត្វញីនិងឈ្មោលមួយគូៗគ្រប់ប្រភេទ ទាំងបក្សាបក្សីឱ្យចូលទៅក្នុងទូក។ ព្រះជាម្ចាស់ក៏បានណែនាំដល់ក្រុមគ្រួសាររបស់លោកណូអេឱ្យរៀបចំម្ហូបអាហារស្តុកទុកសម្រាប់ពួកគេ និងហ្វូងសត្វ។

នៅថ្ងៃទី៧បន្ទាប់ពីលោកណូអេ និងក្រុមគ្រួសាររបស់លោកចូលទៅក្នុងទូក ព្រះជាម្ចាស់បានបិទទ្វារទូក។ ភ្លាមៗនោះស្រាប់តែភ្លៀងបង្អោរចុះមក។ ភ្លៀងបន្តអស់រយៈពេល៤០យប់៤០ថ្ងៃ! វាភ្លៀងមិនឈប់ឈររហូតដល់ទៅលេចភ្នំទាំងឡាយអស់។

មានក្រុមគ្រួសាររបស់លោកណូអេ និងហ្វូងសត្វដែលពួកលោកបានប្រមូលចូលទូកតែប៉ុណ្ណោះដែលរស់រានមានជីវិត។ លោកណូអេទាំងប្រពន្ធ និងកូនប្រុសៗ ព្រមទាំងកូនប្រសាស្រីៗរបស់គាត់ដែលបានទទួលសុវត្ថិភាព ពីព្រោះពួកគេបានជ្រើសរើសស្តាប់បង្គាប់ព្រះជាម្ចាស់យ៉ាងអស់ពីចិត្ត។

នៅទីបញ្ចប់ភ្លៀងក៏ឈប់ ហើយទឹកក៏បានស្រក។ លោកណូអេ និងក្រុមគ្រួសាររបស់លោក ព្រមទាំងហ្វូងសត្វបានចេញពីទូកឈានជើងលើផែនដីជាថ្មីម្តងទៀត។

តើប្អូនៗដឹងទេថាតើកិច្ចការដំបូងបង្អស់ដែលពួកគេបានធ្វើគឺជាអ្វី ? គឺពួកគេថ្វាយបង្គំ និងថ្លែងអំណរព្រះគុណដល់ព្រះជាម្ចាស់!

បន្ទាប់មកព្រះជាម្ចាស់បានដាក់ឥន្ទធនូនៅលើមេឃ ហើយបានចងព្រះបន្ទូលសន្យាមួយយ៉ាងអស្ចារ្យគឺថា ៖ យើងនឹងប្រទានពរឱ្យដល់អ្នក។ ចូរបង្កើតកូនចៅឱ្យបានច្រើនពាសពេញផែនដី។ ឥន្ទធនូដែលយើងដាក់នៅលើមេឃនេះនឹងក្លាយជាសញ្ញាដល់អ្នក ថាផែនដីនេះនឹងមិនត្រូវបំផ្លាញដោយទឹកជំនន់ទៀតទេ។

លោកណូអេ និងក្រុមគ្រួសាររបស់លោកត្រូវបានសុវត្ថិភាពដោយសារព្រះជាម្ចាស់ដែលពួកគេស្រឡាញ់!

> *ខចងចាំ ៖ «ព្រះអម្ចាស់មានព្រះបន្ទូលថា៖ ដោយគេស្ថិតនៅជាប់នឹងយើង យើងនឹងជួយរំដោះគេ យើងនឹងការពារគេព្រោះគេទទួលស្គាល់ថា យើងជាព្រះអម្ចាស់!» ទំនុកតម្កើង ៩១:១៤។*

សង្ខេប ៖ព្រះជាម្ចាស់បានចាត់ឱ្យមានទឹកជំនន់មួយដ៏ធំ ដោយព្រោះតែកិច្ចការអាក្រក់ដែលមនុស្សលោកបានប្រព្រឹត្តនៅលើផែនដី។ ព្រះជាម្ចាស់បានរក្សាជីវិតលោកណូអេ និងក្រុមគ្រួសាររបស់លោកឱ្យបានសង្គ្រោះ ដោយព្រោះតែពួកគេជឿទុកចិត្តលើព្រះអង្គ។ មិនថាមានអ្វីកើតឡើងនៅជុំវិញយើងនោះទេ ព្រះជាម្ចាស់នឹងការពារយើង ពេលយើងជឿទុកចិត្តលើព្រះអង្គ និងស្តាប់បង្គាប់ព្រះអង្គយ៉ាងអស់ពីចិត្ត។

### ការកត់ត្រា និងការស្តាប់សំណូមពរអធិស្ឋាន

### ការចែកចាយ និងការអធិស្ឋានរួមគ្នា

### ការសរសើរតម្កើង និងថ្វាយបង្គំ

### ការប្រទានពរ និងបញ្ចប់កម្មវិធី ៖

អ្នកគ្រូសូមជូនពរប្អូនៗឱ្យស្គាល់ព្រះជាម្ចាស់ និងឱ្យបទពិសោធការការពារថែរក្សារបស់ព្រះអង្គ។







❖ ការចែកកាត

- រូបភាព ត្រូវតែរៀបចំកាត់ឲ្យហើយជាស្រេចមុនពេលនិងចែកចាយ។





- ការផ្គុំកាត





# រូបភាព & ទីបន្ទាល់

# ការនិទានរឿង

- មានវិធីសាស្ត្រ ៥ យ៉ាងដែលជួយអ្នកក្នុងការនិទានរឿងក្នុងព្រះគម្ពីរ ដើម្បីឲ្យក្មេងៗងាយស្រួលស្តាប់ នឹងចងចាំ ៖

1. ធ្វើការសញ្ជឹងគិតអំពីបទគម្ពីរដែលជាសាច់រឿងនេះជាមុនសិន។ អនុញ្ញាតឲ្យសារនៃរឿងនេះប៉ះពាល់ដល់ជីវិតរបស់អ្នកជាមុនសិនមុនពេលដែលអ្នកយកទៅធ្វើការបង្រៀនដល់ក្មេងៗ។

# ការនិទានរឿង

2. ត្រូវមានភាពស៊ាំជាមួយនឹងសាច់រឿង។ សូមធ្វើការអានសាច់រឿងដែលអ្នកត្រូវនិទានឲ្យបានច្រើនដង ហើយនឹងឮៗ ធ្វើដូច្នេះអាចធ្វើឲ្យអ្នកមានភាពជឿជាក់ក្នុងការនិទានរឿង។
3. ហើយសូមធ្វើការពិចារណាអំពីបទគម្ពីរនៅក្នុងសាច់រឿង។

# ការនិទានរឿង

4. មិនត្រូវធ្វើការនិទានរឿងដោយប្រើការអានពីសៀវភៅក្នុងកំឡុងពេលបង្រៀននោះទេ។

OneHope
GOD'S WORD. EVERY CHILD.

# ការនិទានរឿង

5. ក្នុងនាមជាអ្នកនិទានរឿង គឺត្រូវតែគិតពីកន្លែងដែលត្រូវ "ផ្លាស់ប្តូរ" *ផ្លាស់ប្តូរ ទាំងល្បឿន នឹង កម្រិតសម្លេងរបស់អ្នក គឺត្រូវធ្វើឲ្យបានល្អប្រសើរ ក្នុងពេលអ្នកនិយាយ។ ផ្លាស់ប្តូរទាំងកាយវិការ នឹងទឹកមុខរបស់លោកអ្នក ដើម្បីឲ្យស៊ីទៅនឹងស្ថានភាពនៃសាច់រឿងដែលអ្នកបាននិទាន។* ប៉ុន្តែ ភាគច្រើននៃការនិទានរឿងត្រូវមានភាពសប្បាយរីករាយ។ ដើម្បីបញ្ជាក់ថា រឿងរបស់ព្រះជាម្ចាស់គឺជារឿងដែលពិសេសអស្ចារ្យ!

OneHope
GOD'S WORD. EVERY CHILD.

# OneHope Contact

012/099/061/070/093/016

75 43 20